# ទម្រង់ពាក្យស្នើសុំ
## «កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន ឆ្នាំ២០២៦-២០២៧»
«កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍»

**ព័ត៏មានសំខាន់ៗ**

- កាលបរិច្ឆេទកំណត់ឈប់ទទួលពាក្យ គឺ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦
- អាចដាក់ពាក្យតាមរយៈមធ្យោបាយណាមួយខាងក្រោម៖
  - បើមានអីម៉េល សូមផ្ញើមកអីម៉េល thary@cambodianlivingarts.org
  - បើពុំមានអីម៉េល អ្នកអាចផ្ញើតាមលេខតេលេក្រាម ០៨៥ ៣០៣ ៩៧១ (មេត មន្ថារី - Meth Monthary)
  - ឬអ្នកក៏អាចយកមកដាក់ផ្ទាល់នៅការិយាល័យអង្គការសិល្បៈខ្មែរអមតៈនៅ (ផ្ទះលេខ ១៣E ផ្លូវលេខ ៨៣០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ) តំណរទៅកាន់ទីតាំងការិយាល័យ៖ https://maps.app.goo.gl/W1Bcyu5e3Bdezk9f8
- សម្រាប់អ្នកដែលពុំអាចសរសេរបាន ឬមើលឃើញ អាចជ្រើសរើសវិធីផ្សេងក្នុងការដាក់ពាក្យ ដូចជាថតវីដេអូ ដោយឆ្លើយទៅតាមសំណួរនីមួយៗ គ្រប់សំណួរ រយៈពេលសរុបមិនលើស ១០ នាទី។
- សម្រាប់ព័ត៏មានលម្អិតបន្ថែម សូមអានឯកសារ “ទិដ្ឋភាពទូទៅនៃកម្មវិធី”

## ផ្នែកទី ១ ៖ ព័ត៏មានអំពីអ្នក

---

### ១.១ ព័ត៏មានលម្អិតរបស់អ្នក
សូមបំពេញព័ត៏មានខាងក្រោមនៅជួរប្រអប់ខាងស្តាំ៖

| | |
|---|---|
| នាមត្រកូល និងនាមខ្លួន ជាអក្សរខ្មែរ៖ | |
| នាមត្រកូល និងនាមខ្លួន ជាអក្សរឡាតាំង៖ | |
| ឈ្មោះហៅក្រៅ (បើមាន)៖ | |
| ភេទ / អត្តសញ្ញាណយេនឌ័រ / សព្វនាម៖ | |
| ថ្ងៃ ខែ ឆ្នាំកំណើត៖ | |
| ទីកន្លែងកំណើត៖ | |
| ទីលំនៅបច្ចុប្បន្ន៖ | |

| | |
|---|---|
| មុខរបរសព្វថ្ងៃ៖ | |
| ជនជាតិ៖ | |
| លេខទូរស័ព្ទ ដែលភ្ជាប់តេលេក្រាម៖ | |
| អ៊ីម៉េល (បើមាន)៖ | |
| គណនីហ្វេសប៊ុក៖ | |

## ១.២ ការណែនាំសង្ខេបរបស់អ្នក

សូមណែនាំជាសង្ខេបអំពីខ្លួនរបស់អ្នក

| |
|---|
| |

**១.៣ ប្រវត្តិនៃការសិក្សាសិល្បៈវប្បធម៌** (បើមិនធ្លាប់មានប្រវត្តិសិក្សា ប៉ុន្តែមានបទពិសោធន៍ ការងារនៅក្នុងសិល្បៈវប្បធម៌ សូមរំលងសំណួរទី ១.៣ នេះ ហើយបំពេញសំណួរ ១.៥ តែសូមកុំភ្លេចបំពេញសំណួរ ១.៤ )

| ឈ្មោះ និងអាសយដ្ឋាន (សាលា/សមាគម/គ្រូ) | ការសិក្សាសិល្បៈវប្បធម៌ | រយៈពេល | សញ្ញាបត្រទទួលបាន (បើមាន) |
|---|---|---|---|
| ឈ្មោះ.......................................<br>ខេត្ត/ក្រុង.................................. | ផ្នែក..........................<br>ជំនាញ...................... | ពី...............................<br>ដល់............................ | ..................................<br>.................................. |
| ឈ្មោះ.......................................<br>ខេត្ត/ក្រុង.................................. | ផ្នែក..........................<br>ជំនាញ...................... | ពី...............................<br>ដល់............................ | ..................................<br>.................................. |
| ឈ្មោះ.......................................<br>ខេត្ត/ក្រុង.................................. | ផ្នែក..........................<br>ជំនាញ...................... | ពី...............................<br>ដល់............................ | ..................................<br>.................................. |
| ឈ្មោះ.......................................<br>ខេត្ត/ក្រុង.................................. | ផ្នែក..........................<br>ជំនាញ...................... | ពី...............................<br>ដល់............................ | ..................................<br>.................................. |

សូមភ្ជាប់បន្ថែម ប្រសិនបើអ្នកមានប្រវត្តិនៃការសិក្សាសិល្បៈវប្បធម៌ច្រើនជាងនេះ ។ នេះ។ សូមបញ្ជាក់អោយបានលម្អិតបន្តិចអំពី ឈ្មោះនៃជំនាញ និងឈ្មោះសាលា។

## ១.៤ ប្រវត្តិនៃការសិក្សាចំណេះដឹងទូទៅ (បើមាន)

| គ្រឹះស្ថានសិក្សា | ឈ្មោះ និងអាសយដ្ឋាន | រយៈពេលសិក្សា | សញ្ញាបត្រទទួលបាន (បើមាន) |
|---|---|---|---|
| វិទ្យាល័យ | ឈ្មោះ.......................................<br>ខេត្ត/ក្រុង.................................. | ពី...........................<br>ដល់....................... | ...............................................<br>............................................... |
| មហាវិទ្យាល័យ | ឈ្មោះ.......................................<br>ខេត្ត/ក្រុង.................................. | ពី...........................<br>ដល់....................... | ...............................................<br>............................................... |

| | | | |
|---|---|---|---|
| មហាវិទ្យាល័យ | ឈ្មោះ......................................<br>ខេត្ត/ក្រុង.................................. | ពី...........................<br>ដល់........................ | .............................................<br>............................................. |

សូមភ្ជាប់បន្ថែម ប្រសិនបើអ្នកមានប្រវត្តិនៃការសិក្សាចំណេះដឹងទូទៅច្រើនជាងនេះ។ សូមបញ្ជាក់អោយបានលម្អិតបន្តិចអំពីឈ្មោះនៃជំនាញ និងឈ្មោះសាលា។

## ១.៥ បទពិសោធន៍ការងារក្នុងវិស័យសិល្បៈវប្បធម៌ ឬសិល្បៈសហសម័យ (បើមាន)

| ឈ្មោះ និងអាសយដ្ឋានអង្គភាព | រយៈពេលនៃការបំពេញការងារ | តួនាទី |
|---|---|---|
| ១. ឈ្មោះ.............................................<br>ខេត្ត/ក្រុង............................................. | ពី...............................................<br>ដល់............................................... | .............................................<br>............................................. |
| សូមបរិយាយបន្ថែមពីបទពិសោធន៍ (ឧ. ទំនួលខុសត្រូវការងារ ជាដើម)៖ | | |
| ២. ឈ្មោះ.............................................<br>ខេត្ត/ក្រុង............................................. | ពី...............................................<br>ដល់............................................... | .............................................<br>............................................. |
| សូមបរិយាយបន្ថែមពីបទពិសោធន៍ (ឧ. ទំនួលខុសត្រូវការងារ ជាដើម)៖ | | |
| ៣. ឈ្មោះ.............................................<br>ខេត្ត/ក្រុង............................................. | ពី...............................................<br>ដល់............................................... | .............................................<br>............................................. |
| សូមបរិយាយបន្ថែមពីបទពិសោធន៍ (ឧ. ទំនួលខុសត្រូវការងារ ជាដើម)៖ | | |

សូមភ្ជាប់បន្ថែម ប្រសិនបើអ្នកមានបទពិសោធន៍ការងារក្នុងវិស័យសិល្បៈវប្បធម៌ច្រើនជាងនេះ ។ អាចដាក់ជាត្រេៗ និងលម្អិតបន្តិចពីការងារជាក់លាក់របស់អ្នកនៅក្នុងការងាររួមនោះ

# ផ្នែកទី ២ ៖ លក្ខណៈសម្បត្តិ

សូមបញ្ជាក់ថាអ្នកមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

| លក្ខណៈសម្បត្តិ | សូមសរសេរ **បាទ/ចាំ ឬ ទេ** |
|---|---|
| មានអាយុចាប់ពី ២០ ឆ្នាំ | |
| ជាពលរដ្ឋកម្ពុជា ឬកាន់ទិដ្ឋាការ K-Visa និងកំពុងរស់នៅក្នុងប្រទេសកម្ពុជា | |
| រៀនជំនាញសិល្បៈវប្បធម៌ណាមួយបានយ៉ាងតិច ៣ ឆ្នាំ ឬ<br>ធ្វើការក្នុងវិស័យសិល្បៈវប្បធម៌ ឬសិល្បៈសហសម័យ យ៉ាងតិច ៣ ឆ្នាំ | |
| មានគោលបំណង និងឆន្ទៈ អភិវឌ្ឍជំនាញ ឬអាជីពរបស់ខ្លួននៅក្នុងវិស័យសិល្បៈវប្បធម៌ ឬសិល្បៈសហសម័យ ឱ្យឈានទៅរកកម្រិតអាជីព | |

# ផ្នែកទី ៣ ៖ ចំណាប់អារម្មណ៍របស់អ្នកនៅក្នុងកម្មវិធី

## ៣.១ ការជ្រើសរើសប្រភេទអាហារូបករណ៍និងវគ្គសិក្សាដែលស្នើសុំ (អាចគូសបានតែមួយប្រអប់)

| ប្រភេទអាហារូបករណ៍ | ឈ្មោះវគ្គសិក្សាដែលអាចស្នើសុំ មានដូចតទៅ៖ | សូមគូស ☑ នូវវគ្គសិក្សាដែលស្នើសុំ | ការផ្តល់ជូនការគាំទ្រអាហារូបករណ៍រយៈពេល |
|---|---|---|---|
| **អាហារូបករណ៍អភិវឌ្ឍន៍ជំនាញសិល្បៈ និងសិល្បៈសហសម័យ** | ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ<br>(សូមបញ្ជាក់ពីជំនាញ.............................................................................) | ☐ | ៣ ឆ្នាំ |
| | ហ្វឹកហាត់នៅសាលាឬជាមួយគ្រូឯកជន នៃសិល្បៈវប្បធម៌ ឬសិល្បៈសហសម័យ<br>(សូមបញ្ជាក់ពីជំនាញ.............................................................................) | ☐ | ៣ ឆ្នាំ |
| | វគ្គសិក្សាផ្សេងៗ ពាក់ព័ន្ធនឹងសិល្បៈសហសម័យ<br>(សូមបញ្ជាក់ពីជំនាញ.............................................................................) | ☐ | ៣ ឆ្នាំ |

| | | | |
|---|---|---|---|
| **អាហារូបករណ៍ អភិវឌ្ឍន៍ ជំនាញមិនមែន សិល្បៈ** | ភាសាអង់គ្លេសឬបារាំងទូទៅ (វគ្គក្រៅម៉ោង, ពេញម៉ោង) | ☐ | ៣ ឆ្នាំ |
| | ជំនាញកុំព្យូទ័រទូទៅ | ☐ | ៣ ឆ្នាំ |
| | មហាវិទ្យាល័យ (ឧ. គ្រប់គ្រង, ភាសាអង់គ្លេស, -ល-)<br>(សូមបញ្ជាក់ពីជំនាញ..........................................................................) | ☐ | ៣ ឆ្នាំ |
| **ឬពាក់ព័ន្ធ សិល្បៈវប្បធម៌ និងសិល្បៈសហសម័យ** | អនុបណ្ឌិត (ឧ. បុរាណវិទ្យា, គ្រប់គ្រង, រដ្ឋបាល, -ល-)<br>(សូមបញ្ជាក់ពីជំនាញ..........................................................................) | ☐ | ៣ ឆ្នាំ |
| | វគ្គសិក្សាផ្សេងៗ<br>(សូមបញ្ជាក់ពីជំនាញ.........................................................................) | ☐ | |

***កំណត់ចំណាំសំខាន់៖**

(១) ការផ្តល់ជូនការគាំទ្រអាហារូបករណ៍នឹងមានរយៈពេល៣ឆ្នាំពេញ និងមានរយៈពេលតែ៣ឆ្នាំប៉ុណ្ណោះ ក្នុងករណីបេក្ខជនដាក់ពាក់ស្នើរៀនបរិញ្ញាបត្រ ឬជំនាញផ្សេងៗ៖

- ប្រសិនបើបេក្ខជនដាក់ស្នើសម្រាប់ការគាំទ្ររៀនបរិញ្ញាបត្រសម្រាប់ ៤ ឬ ៥ ឆ្នាំពេញ នៃបរិញ្ញាបត្រនោះ ការផ្តល់ជូនការគាំទ្រអាហារូបករណ៍នឹងមានរយៈពេលតែ៣ឆ្នាំប៉ុណ្ណោះ។
- ប្រសិនបើបេក្ខជនកំពុងរៀនបរិញ្ញាបត្រនៅឆ្នាំទី៣ ៤ ឬទី៥ ហើយត្រូវការគាំទ្រអាហារូបករណ៍ដើម្បីបញ្ចប់ឆ្នាំ នៃបរិញ្ញាបត្រ ឆ្នាំដែលនៅសេះសល់ បេក្ខជននឹងតម្រូវអោយគិតទៅលើថាតើនឹងយកថវិកានៃអាហារូបករណ៍ ទៅធ្វើគម្រោង ឬសិក្សាអ្វីមួយបន្ថែម ដែលរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់បេក្ខជន នៅក្នុងវិស័យសិល្បៈសហសម័យ។
- ប្រសិនបើបេក្ខជនដាក់ស្នើសម្រាប់ការគាំទ្ររៀនអនុបណ្ឌិត ដែលមានរយៈពេល២ឆ្នាំ ឆ្នាំដែលនៅសេះសល់ បេក្ខជននឹងតម្រូវអោយគិតទៅលើថាតើនឹងយកថវិកានៃអាហារូបករណ៍ ទៅធ្វើគម្រោង ឬសិក្សាអ្វីមួយបន្ថែម ដែលរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់បេក្ខជន នៅក្នុងវិស័យសិល្បៈសហសម័យ។
- ប្រសិនបើបេក្ខជនដាក់ស្នើសម្រាប់ការគាំទ្ររៀនចំណេះជំនាញពាក់ព័ន្ធណាមួយ ហើយចំណេះជំនាញនោះ ត្រូវការពេលតែ១ ឬទៅ២ឆ្នាំនោះទេ បេក្ខជននឹងតម្រូវអោយគិតទៅលើថាតើនឹងយកថវិកានៃអាហារូបករណ៍ ទៅធ្វើគម្រោង ឬសិក្សាអ្វីមួយបន្ថែម ដែលរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់បេក្ខជន នៅក្នុងវិស័យសិល្បៈសហសម័យ។

(២) ចំពោះបេក្ខជនស្នើសុំវគ្គសិក្សាហ្វឹកហាត់ជាមួយគ្រូសិល្បៈឯកជន ហើយចង់ស្នើសុំទិញឧបករណ៍ភ្លេង សូមបញ្ជាក់នៅទីនេះពីឈ្មោះឧបករណ៍ភ្លេង និងតម្លៃឧបករណ៍នោះ។ សិល្បៈខ្មែរអមតៈអាចនឹងពិចារណាលើលទ្ធភាព ប្រសិនបើបេក្ខជន ជាប់ជ័យលាភីពិតជាមានតម្រូវការខ្លាំង។

............................................................................................................................................................................................................

## ៣.២ កន្លែងឬគ្រូដែលអ្នកស្នើសុំរៀនជាមួយ

| | |
|---|---|
| ឈ្មោះ (សាលា សមាគម ឬគ្រូ ដែលអ្នក បានឈ្វេងយល់ ស្រាវជ្រាវ ឬសាកសួរព័ត៌មាន អំពីជំនាញ ដែលចង់រៀន)៖ | |

| | |
|---|---|
| អាសយដ្ឋាន (សាលា សមាគម ឬគ្រូ)៖ | |
| លេខទូរស័ព្ទទំនាក់ទំនង (បើមាន)៖ | |
| អ៊ីម៉េល (បើមាន)៖ | |

**៣.៣ តើអ្នកមានគោលដៅដូចម្តេច ក្នុងវិស័យសិល្បៈវប្បធម៌ ឬសិល្បៈសហសម័យ? ហើយតើកម្មវិធីអាហារូបករណ៍នេះ អាចជួយអ្នកបានយ៉ាងដូចម្តេច ដើម្បីសម្រេចគោលដៅនោះ?**

អ្នកក៏អាចបង្ហាញបន្ថែមអំពីការយល់ឃើញ ឬការដកពិសោធន៍របស់អ្នកជាមួយសិល្បៈសហសម័យបានផងដែរ ។

**៣.៤ តើមូលហេតុអ្វី ដែលសិល្បៈខ្មែរអមតៈ គួរតែជ្រើសរើសអ្នកឲ្យទទួលបាន អាហារូបករណ៍នេះ?**

**៣.៥** សិល្បៈខ្មែរអមតៈផ្តល់ប្រាក់អាហារូបករណ៍ ១,៥០០ ដុល្លារ ក្នុង១ឆ្នាំ។ ប្រាក់នឹងត្រូវបើក ជា៤ដង ដោយបើកប្រាក់ម្តង ៣៧៥ដុល្លារ។

**តើអ្នកនឹងចាត់ចែងប្រាក់អាហារូបករណ៍នេះដូចម្តេចសម្រាប់គោលបំណងនៃការសិក្សា និងការអភិវឌ្ឍខ្លួន?**

## ផ្នែកទី ៤ ៖ ផ្សេងៗ

---

### ៤.១ តើមានអ្វីផ្សេងទៀតដែលអ្នកចង់ប្រាប់យើងដែរឬទេ?

| |
|---|
| |

### ៤.២ កិច្ចព្រមព្រៀង និងការប្ដេជ្ញារបស់បេក្ខជនទៅលើកម្មវិធីអាហារូបករណ៍

ប្រសិនបើ ខ្ញុំត្រូវបានជ្រើសរើសជាបេក្ខជនជ័យលាភីនៃ **កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន** របស់សិល្បៈខ្មែរអមតៈ ខ្ញុំប្ដេជ្ញាថា នឹងអនុវត្តតាមគោលការណ៍ និងសកម្មភាពសំខាន់ៗ របស់កម្មវិធីអាហារូបករណ៍ដូចខាងក្រោម៖

- មានវត្តមានក្នុងថ្នាក់រៀនដែលបានស្នើសុំអាហារូបករណ៍យ៉ាងហោចណាស់ ៩០% ក្នុង ១ត្រីមាស (៣ខែ)
- ផ្ញើរបាយការណ៍ប្រចាំត្រីមាស (៣ខែម្ដង) ស្ដីពីលទ្ធផលនៃការសិក្សាពីសាលាឬគ្រូឯកជន
- ត្រូវចូលរួមកម្មវិធីបណ្ដុះគុណតម្លៃដែលរៀបចំដោយសិល្បៈខ្មែរអមតៈ ឱ្យបានទៀងទាត់ និងអនុវត្តរាល់សកម្មភាពក្នុងកម្មវិធីបណ្ដុះគុណតម្លៃទាំងអស់ ផ្អែកលើកាលវិភាគដែលចែកជូន
- ប្រើប្រាស់ប្រយោជន៍ពីការឧបត្ថម្ភអាហារូបករណ៍ ឱ្យស្របទៅនឹងគោលបំណងនៃកម្មវិធី
- បើកចិត្តរៀនសូត្រនូវអ្វីដែលថ្មីៗ និងមានឆន្ទៈខ្ពស់ក្នុងការអភិវឌ្ឍខ្លួនឯង និងសិល្បៈកម្ពុជា។

ខ្ញុំយល់ច្បាស់ថាការអនុវត្តមិនបានតាមគោលការណ៍នៃកម្មវិធីនេះអាចនឹងត្រូវបញ្ឈប់ពីកម្មវិធីអាហារូបករណ៍នេះ។

ហត្ថលេខាបេក្ខជន ..............................................

ឈ្មោះ ............................................ កាលបរិច្ឆេទ ............................................

<u>សូមអរគុណច្រើនចំពោះចំណាប់អារម្មណ៍របស់អ្នកលើកម្មវិធីនេះ!</u>

សិល្បៈខ្មែរអមតៈ

**ឧបសម្ព័ន្ធ៖** សេចក្ដីសង្ខេបអំពីកម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំបន្តថ្មី

កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន គឺជាគំនិតផ្ដួចផ្ដើមស្នូលមួយសម្រាប់ការអភិវឌ្ឍ សមត្ថភាព ដែលមានគោលបំណងគាំទ្រសិល្បករ និងប្រត្តិបត្តិករវប្បធម៌កម្ពុជា ដែលបានកំពុងចាប់ផ្ដើម ដើម្បីពង្រឹងសមត្ថភាព វិជ្ជាជីវៈរបស់ពួកគាត់ និងរួមចំណែកដល់ការអភិវឌ្ឍសិល្បៈសហសម័យ នៅកម្ពុជា។ កម្មវិធីជ្រើសរើសផែនការសិក្សាថ្មី ដែលមានលក្ខណៈបន្តជាប់គ្នារយៈពេល ៣ ឆ្នាំពេញ ដែលរួមបញ្ចូល៖ ការអភិវឌ្ឍខ្លួន ការដកពិសោធន៍នូវ សិល្បៈសហសម័យ និងការត្រៀមខ្លួនទៅកាន់ ការក្លាយខ្លួនជាអ្នកអាជីព ឬចាប់យកវិជ្ជាជីវៈនោះ។ កម្មវិធីសិក្សានៅក្នុង អាហារូបករណ៍ថ្មីនេះ ត្រូវបានរៀបចំជារចនាសម្ព័ន្ធសិក្សាបែបយុទ្ធសាស្ត្រ បីដំណាក់កាល ដើម្បីអោយស្រប ទៅកាន់ការកសាងសមត្ថភាព សិល្បៈសហសម័យ និងការអភិវឌ្ឍភាពជាអ្នកដឹកនាំ។

**ឆ្នាំទី១៖ មូលដ្ឋាននៃការអភិវឌ្ឍខ្លួន និងវិជ្ជាជីវៈ**

ឆ្នាំទី១ ផ្ដោតលើការកសាងការយល់ដឹងអំពីខ្លួនឯង ការងារជាក្រុម និងមូលដ្ឋាននៃភាពជាអ្នកដឹកនាំ របស់ខ្លួន សម្រាប់សិល្បករ និងប្រត្តិបត្តិករវប្បធម៌កម្ពុជា ដែលបានកំពុងចាប់ផ្ដើម។ អ្នកទទួលបានអាហារូបករណ៍ នឹងទទួលបានការអភិវឌ្ឍជំនាញជីវិត និងវិជ្ជាជីវៈសំខាន់ៗ រួមមាន ការដឹកនាំខ្លួនឯង ភាពអត់ធ្មត់និងភាពរឹងមាំ ការកំណត់ចក្ខុវិស័យ និងគុណតម្លៃ ការធ្វើផែនការអាជីព ការគ្រប់គ្រង ពេលវេលា និងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។ ការសិក្សាត្រូវបានអនុវត្តតាមរយៈសិក្ខាសាលា ការធ្វើលំហាត់ឆ្លុះបញ្ចាំងខ្លួនឯង និងសកម្មភាពអនុវត្តផែនការជាក់ស្ដែង ដើម្បីពង្រឹងភាពត្រៀមខ្លួនសម្រាប់ ការចាប់យកជាវិជ្ជាជីវៈ និងសមត្ថភាពធ្វើសកម្មភាព ដោយឯករាជ្យ ក្នុងការអនុវត្តសិល្បៈច្នៃប្រតិដ្ឋ។

**ឆ្នាំទី២៖ ការស្វែងយល់នូវសិល្បៈសហសម័យ និងការអភិវឌ្ឍគំនិតវិភាគ**

ឆ្នាំទី២ ពង្រីកការយល់ដឹងរបស់ អ្នកទទួលបានអាហារូបករណ៍ ទៅកាន់ការអនុវត្តសិល្បៈសហសម័យ ប្រព័ន្ធអេកូស៊ីស្ទឹមរបស់សិល្បៈច្នៃប្រតិដ្ឋ និង ការគិតបែបជាអ្នកដឹកនាំ និងបែបសិល្បៈ។ តាមរយៈ ការសន្ទនាជាមួយសិល្បករ ការទស្សនកិច្ចទីតាំង ការសិក្សាសិល្បៈអន្តរវិស័យឬអន្តរវិធីសាស្ត្រ និងវគ្គពិភាក្សាស៊ីជម្រៅ អ្នកទទួលបានអាហារូបករណ៍នឹង ទទួលបានបទពិសោធន៍ និងការយល់ដឹង អំពីដំណើរការច្នៃប្រតិដ្ឋសហសម័យ ការជជែកវែកញែកនូវវប្បធម៌ និងបរិយាកាសនៃវិជ្ជាជីវៈសិល្បៈ។ ដំណាក់កាលនេះផ្ដោតលើ ការអភិវឌ្ឍគំនិតវិភាគ ទស្សនៈបែបសិល្បៈ និងការយល់ដឹងអំពីប្រព័ន្ធអេកូស៊ីស្ទឹមសិល្បៈ ដើម្បីគាំទ្រការអភិវឌ្ឍគុណភាពសិល្បៈសហសម័យ នៅកម្ពុជា។

**ឆ្នាំទី៣៖ ដំណើរការទៅកាន់ការចាប់យកជាវិជ្ជាជីវៈ កិច្ចសហការ និងការដកពិសោធន៍លក្ខណៈតំបន់**

ឆ្នាំទី៣ គឺជាការបញ្ចប់ដំណើរការសិក្សាអាហារូបករណ៍ ដោយផ្ដោតលើការគិតទៅលើគម្រោងច្នៃប្រតិដ្ឋ ការសហការគ្នា និងការដកពិសោធន៍នៃវិស័យសិល្បៈនៅកម្រិតតំបន់។ អ្នកទទួលបានអាហារូបករណ៍ នឹងធ្វើការអភិវឌ្ឍ និងបង្ហាញគំនិត គម្រោងច្នៃប្រតិដ្ឋ តាមរយៈការសិក្សាលក្ខណៈក្រុម និងលំហាត់ធ្វើផែនការនៃគម្រោងជាក់ស្ដែង។ កម្មវិធីក៏រួមបញ្ចូល ទស្សនកិច្ចសិក្សានៅក្នុងតំបន់ ដើម្បីពង្រឹងការសិក្សាឆ្លងវប្បធម៌ និងការអភិវឌ្ឍបណ្ដាញនៃអាជីព។ ឆ្នាំនេះបញ្ចប់ដោយ ការធ្វើបទបង្ហាញចែករំលែកចំណេះដឹងជាសាធារណៈ អនុញ្ញាតឱ្យអ្នកទទួលបានអាហារូបករណ៍បង្ហាញលទ្ធផលសិក្សា និងចែករំលែកចំណេះដឹងត្រឡប់ទៅសហគមន៍សិល្បៈ។